

# សៀវភៅណែនាំសេវាកម្មថែទាំមនុស្សចាស់ជរា

Southern
Migrant & Refugee Centre



## ស្វាគមន៍មកកាន់សៀវភៅណែនាំសេវាកម្ម

សៀវភៅនេះ ជាសៀវភៅណែនាំពីការផ្តល់សេវាកម្មមើលថែទាំមនុស្សចាស់ជរារបស់យើងខ្ញុំ។ យើងខ្ញុំមានការផ្តល់ជូននូវសេវាកម្មជំនួយជាច្រើនដែលមានអត្ថប្រយោជន៍ដល់សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្តរបស់លោកអ្នក។
សូមធ្វើការទាក់ទងមកកាន់យើងខ្ញុំប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍ក្នុងការចូលរួមកម្មវិធីណាមួយដែលមាននៅក្នុងសៀវភៅណែនាំនេះ។ ប្រសិនបើអ្នកចង់ដឹងបន្ថែមអំពីកម្មវិធីណាមួយ, យើងខ្ញុំក៏សប្បាយចិត្តក្នុងការផ្តល់ជូននូវព័ត៌មានបន្ថែម។

## អំពីបុគ្គលិក

យើងខ្ញុំមានបុគ្គលិកដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាពក្នុងការនិយាយភាសាដទៃក្រៅពីភាសាអង់គ្លេសដែលអាចបំពេញការងារបានតាមតម្រូវការរបស់លោកអ្នក។

## ការធ្វើតេស្តវាយតម្លៃ

ការធ្វើតេស្តវាយតម្លៃគឺមានភាពចំបាច់ណាស់សម្រាប់យើងខ្ញុំក្នុងការមើលថែទាំលោកអ្នកក្នុងគ្រដែលអ្នកប្រើប្រាស់ សេវាកម្មណាមួយរបស់យើងខ្ញុំ។
វាពាក់ព័ន្ធនឹងការពិគ្រោះយោបល់ជាមួយនឹងបុគ្គលិកសម្របសម្រួលកម្មវិធីផងដែរ។

## ផែនការគោលដៅទទួលការថែទាំដោយផ្ទាល់ (Goal Directed Care Plan) របស់លោកអ្នក

ផែនការគោលដៅទទួលការថែទាំដោយផ្ទាល់ គឺជាផែនការដែលលោកអ្នកពិគ្រោះជាមួយនឹងបុគ្គលិកអ្នកសម្របសម្រួលកម្មវិធីអំពីតម្រូវការរបស់អ្នក និងលទ្ធផលដែលអ្នកចង់សម្រេចក្នុងការទទួលសេវាកម្មរបស់យើងខ្ញុំ។
ផែនការគោលដៅទទួលការថែទាំដោយផ្ទាល់របស់លោកអ្នកនឹងត្រូវបានធ្វើការត្រួតពិនិត្យជារៀងរាល់ឆ្នាំ ឬនៅពេលណាដែលស្ថានការរបស់លោកអ្នកមានការផ្លាស់ប្តូរ។
សេវាកម្មយើងខ្ញុំអាចផ្តល់ជូននូវជំនួយជាច្រើនទៅកាន់លោកអ្នក ប៉ុន្តែយើងខ្ញុំក៏ត្រូវការៗនិយាយប្រាប់ពីតម្រូវការចាំបាច់របស់លោកអ្នកផងដែរ៖

- ផ្តល់ដំណឹងដល់អ្នកសម្របសម្រួលកម្មវិធីអំពីកម្មវិធីសេវាកម្មដែលលោកអ្នកមានចំណាប់អារម្មណ៍។
- លោកអ្នកអាចនាំសមាជិកគ្រួសារ ឬមិត្តភក្តិមកចូលរួមប្រជុំបាន។
- លោកអ្នកអាចធ្វើការត្រួតពិនិត្យមើល ឬធ្វើការផ្លាស់ប្តូរផែនការបានគ្រប់ពេលវេលា។



## សេវាកម្មការថែទាំមនុស្សចាស់ជរា

សេវាកម្មអ្នកថែទាំ និងការថែទាំមនុស្សចាស់ជរាយើងខ្ញុំមានដូចខាងក្រោម៖

- សេវាកម្មផ្តល់ជូនជំនួយពីអ្នកឯកទេស (អាយុលើសពី៦៥ឆ្នាំ)
- សេវាកម្មផ្តល់ជូនជំនួយនិងការអនុញ្ញាតប្រើប្រាស់ (អាយុក្រោម៦៥ឆ្នាំ)
- ក្រុមគាំទ្រជំនួយពីសង្គម
- កម្មវិធីសំបុក
- កម្មវិធីដំណើរកម្សាន្ត
- កម្មវិធីជរាភាពវិជ្ជមាន ការបណ្តុះបណ្តាលកម្លាំង និងការធ្វើលំហាត់ប្រាណដោយទឹកក្តៅអុនៗ
- សេវាកម្មព្យាបាលសុខភាពសម្ព័ន្ធមិត្ត ការធ្វើលំហាត់ប្រាណដោយទឹកក្តៅអុនៗ
- សេវាកម្មផ្តល់ជំនួយផ្ទាល់ខ្លួនពីសង្គម (ការធ្វើទស្សនកិច្ចមិត្តភាព)
- គម្រោងអ្នកស្ម័គ្រចិត្តមើលថែទាំមនុស្សចាស់ជរា (ACVVS)
- ជំនួយដល់អ្នកថែទាំមនុស្សចាស់ជរា
- ការសម្រាកលំហែបត់បែនតាមតម្រូវការ
- កម្មវិធីសម្រាកលំហែតាមការកំណត់នៃមជ្ឈមណ្ឌល
- កម្មវិធីសម្រាកលំហែពាក់កណ្តាលសប្តាហ៍តាមការកំណត់នៃមជ្ឈមណ្ឌល



## សេវាកម្មផ្តល់ជូនជំនួយពីអ្នកឯកទេស (អាយុលើសពី៦៥ឆ្នាំ)

សេវាកម្មផ្តល់ជូនជំនួយពីអ្នកឯកទេសយើងខ្ញុំជួយមនុស្សចាស់អាចរកបាននូវសេវាកម្មជំនួយ
និងអាចមានសិទ្ធិក្នុងការប្រើប្រាស់បាននូវសេវាកម្មដែលចាំបាច់។
ជាសេវាកម្មដែលបំពេញបាននូវតម្រូវការបច្ចេកទេសចំពោះមនុស្សចាស់ដែលរស់នៅក្នុងគេហដ្ឋា
នជាមួយនឹងលក្ខខណ្ឌព្យាបាល ឬតម្រូវការឯកទេស។

បុគ្គលដែលតម្រូវការប្រើប្រាស់សេវាកម្មមួយនេះត្រូវមានការណែនាំពីបណ្តាញផ្ទាល់របស់យើងខ្ញុំ
ឬតាមរយៈមជ្ឈមណ្ឌលផ្តល់សេវាផ្សេងៗទៀត។
ក្រុមការងារយើងខ្ញុំទទួលស្តាប់នូវរាល់ចំណុចព្រួយបារម្ភរបស់អ្នក
ទន្ទឹមនឹងពេលដែលយើងខ្ញុំស្វែងរកសេវាកម្មដែលស្របនឹងតម្រូវការរបស់លោកអ្នក។
យើងមានផ្តល់ជួយតាមរយៈការជួបមុខសន្ទនាដោយផ្ទាល់ ឬតាមរយៈទូរស័ព្ទ
ហើយរក្សាទំនាក់ទំនងតទៅមុខទៀត
ដូច្នេះលោកអ្នកអាចទុកចិត្តបានដែលយើងខ្ញុំនៅក្បែរលោកអ្នករាល់ជំហានទាំងអស់។

## កម្មវិធីគាំពារនិងការអនុញ្ញាតឱ្យប្រើប្រាស់ (អាយុក្រោម៦៥ឆ្នាំ)

កម្មវិធីគាំពារនិងការអនុញ្ញតឱ្យប្រើប្រាស់យើងខ្ញុំជួយដល់មនុស្សដែលមិនមានសមត្ថភា
ពក្នុងការស្វែងរកសេវាកម្មជំនួយ និងប្រើប្រាស់សេវាកម្មដែលចាំបាច់។

កម្មវិធីនេះជួយដល់បុគ្គលក្នុងការស្វែងរកសេវាកម្មដែលផ្តល់ប្រយោជន៍ជំនួយល្អបំផុត
ដោយផ្អែកលើមតិតម្រូវការរបស់បុគ្គល
និងជួយធ្វើទំនាក់ទំនងទៅកាន់សេវាកម្មទាំងនោះ
រួមទាំងសេវាកម្មរបស់គ្រោងការធានារ៉ាប់រងពិការភាពជាតិ។

## ក្រុមគាំពារជំនួយសង្គម

ក្រុមគាំពារជំនួយសង្គមយើងខ្ញុំគឺការជួបជុំជាទៀងរាល់សប្តាហ៍ដែលជួយរក្សា និងបង្កើនភាពប្រសើរនៃសុខភាពផ្លូវចិត្ត ព្រមទាំងរាប់អានបានមិត្តភក្តិថ្មីៗ។ ក្រុមទាំងនេះគឺរៀបចំឡើងដោយក្រុមការងារដែលមានភាពរួសរាយរាក់ទាក់ និងផ្តល់ជូននូវក្រុមជួបជុំដែលមានវប្បធម៌ចម្រុះ ឬក្រុមវប្បធម៌រួមជាក់លាក់។

យើងខ្ញុំមានក្រុមគាំពារជំនួយសង្គមជាច្រើនដែលអ្នកអាចជ្រើសរើសយកបាន៖

- ក្រុមវប្បធម៌ចម្រុះ
- ក្រុមវប្បធម៌ចិន
- ក្រុមវប្បធម៌ខ្មែរ
- ក្រុមបុរសសុទ្ធ
- ក្រុមវប្បធម៌ហ្វីលីពីន
- ក្រុមវប្បធម៌អេស្ប៉ាញ
- ក្រុមវប្បធម៌វៀតណាម

## កម្មវិធីដំណើរកម្សាន្ត

កម្មវិធីដំណើរកម្សាន្តរបស់ SMRC គឺមានភាសាជាក់លាក់ដែលដឹកនាំផ្តល់ជូនដោយក្រុមការងារដែលមានវប្បធម៌ចម្រុះពីររបស់យើងខ្ញុំ។ កម្មវិធីដំណើរកម្សាន្តយើងខ្ញុំផ្តល់ឪកាសឱ្យអតិថិជនមានការចូលរួមក្នុងសកម្មភាពសង្គមដទៃពីសង្គមវប្បធម៌របស់ពួកគាត់ដែលធ្វើដំណើរកម្សាន្តទៅកាន់កន្លែងផ្សេងៗជាច្រើន។

យើងខ្ញុំមានផ្តល់ជូនអាហារថ្ងៃត្រង់ និងមធ្យោបាយធ្វើដំណើរជូនក្រុមកម្សាន្តទៅកាន់កន្លែងមួយចំនួនខាងក្រោមនេះ៖

- ប៉ូឡូញ (ទៀងរាល់ខែ)
- អេស្ប៉ាញ (ទៀងរាល់ពីរសប្តាហ៍)
- រ៉ូម៉ានី (ទៀងរាល់ខែ)
- ទួរគី (ទៀងរាល់ខែ)

## កម្មវិធីសំបុក

កម្មវិធីសំបុកគឺជាកម្មវិធីគាំទ្រជំនួយសង្គមដែលលើកទឹកចិត្តបុគ្គលនីមួយៗក្នុងការអបអរសាទរនិងលើកតម្កើងរបបអាហារ ព្រមទាំងសុខុមាលភាពតាមរយៈការបណ្តុះបណ្តាលការស្រឡាញ់ថែរក្សាសួនចម្ការ។

កម្មវិធីសំបុកយើងខ្ញុំជួយបង្កើនកម្រិតតរស់នៅរបស់បុគ្គលម្នាក់ៗដោយផ្តល់ជូននូវជំនួយសង្គមប្រចាំសប្តាហ៍ទាក់ទងនឹងភាពចម្រើនលូតលាស់ និងការបរិភោគអាហារប្បធមិចម្រុះដែលមានផាសុកភាព។ កម្មវិធីនេះមានគោលបំណងលើកបង្កើនទាំងសុខភាពផ្លូវកាយ និងផ្លូវចិត្តនៃបុគ្គលដែលចូលរួម។បុគ្គលចូលរួមនឹងទទួលបានចំណេះ និងអនុវត្តតាមមិត្តថ្មីៗដែលមានចិត្តគំនិតប្រហាក់ប្រហែលគ្នា។

ក្រុមទាំងនេះមានដំណើរការជារៀងរាល់ថ្ងៃ។

## កម្មវិធីគំនិតច្នៃប្រឌិត

កម្មវិធីគំនិតច្នៃប្រឌិត (Creative Minds program) គឺជាកម្មវិធីក្រុមវប្បធមិចម្រុះដែលនាំយកនូវគំនិតច្នៃប្រឌិតមកកាន់ជីវិត។ កម្មវិធីនេះជួយនាំបុគ្គលចូលរួមសកម្មភាពសិល្បៈស្ថិតក្នុងបរិយាកាសដែលមានភាពរួសរាយរាក់ទាក់។ គម្រោងសិល្បៈជាច្រើនចាប់ផ្តើមរៀងរាល់សប្តាហ៍ទីពីរដែលស្របនឹងចំណូលចិត្តនៃបុគ្គលនីមួយៗ ហើយការផ្តល់ជូននូវអាហារសម្រន់ដែលជួយឱ្យមានការទំនាក់ទំនងរវាងបុគ្គលម្នាក់ៗ។

កម្មវិធីនេះដំណើរការរៀងរាល់ពីរសប្តាហ៍។ មានផ្តល់ជូនមធ្យោបាយធ្វើដំណើរប្រសិនបើត្រូវការ។









## សេវាកម្មព្យាបាលសុខភាពសម្ព័ន្ធមិត្ត

សេវាកម្មព្យាបាលសុខភាពសម្ព័ន្ធមិត្ត SMRC ជួយលើកតម្កើនសុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត។
កម្មវិធីនេះធ្វើឡើងក្នុងការរក្សាសុខភាពផ្លូវកាយ ឬជួយឱ្យកាន់តែមានភាពរីកចម្រើនដោយបង្កើនតុល្យភាព កម្លាំង ភាពរហ័សរហួន និងកាយសម្បទា។
អ្នកជំនាញលំហាត់ប្រាណអាចត្រូវបានរៀបចំក្នុងការអនុវត្តផែនការកាយសម្បទាត្រូវតាមតម្រូការរបស់លោកអ្នក។

យើងខ្ញុំមានដំណើរការកម្មវិធីកាយសម្បទាមួយចំនួនរៀងរាល់សប្តាហ៍៖

- ក្រុមបណ្តុះបណ្តាលកម្លាំង Cardinia និងធ្វើលំហាត់ប្រាណដោយទឹកក្តៅអុនៗ
- ក្រុមបណ្តុះបណ្តាលកម្លាំង Dandenong
- ក្រុមធ្វើលំហាត់ប្រាណដោយទឹកក្តៅអុនៗ Noble Park
- ក្រុមបណ្តុះបណ្តាលកម្លាំង Casey
- ក្រុមធ្វើលំហាត់ប្រាណដោយទឹកក្តៅអុនៗ Casey
- ក្រុមបណ្តុះបណ្តាលកម្លាំងស្ត្រីដារី (Dari Ladies)

## សេវាកម្មផ្តល់ជំនួយផ្ទាល់ខ្លួនពីសង្គម (ទស្សនកិច្ចមិត្តភាព)

កម្មវិធីទស្សនកិច្ចមិត្តភាពគឺជាកម្មវិធីជំនួយសង្គមដែលផ្តល់ជូននូវមិត្តភាព និងផ្តល់ជំនួយដល់បុគ្គលដែលមានអាយុលើសពី៦៥ឆ្នាំដែលរស់នៅក្នុងផ្ទះ ហើយមិនមានទទួលបាននូវកញ្ចប់ថែទាំក្នុងផ្ទះ (Home Care Package)។

កម្មវិធីនេះផ្តល់ជំនួយដល់អ្នកដែលមានភាពឯកការក្នុងសង្គមតាមរយៈការទស្សនកិច្ចសួរសុខទុក្ខពីក្រុមការងារស្ម័គ្រចិត្តដែលចេះភាសាចម្រុះរបស់យើងខ្ញុំ។
ក្រុមសួរសុខទុក្ខយើងខ្ញុំក៏អាចជួយដល់ការធ្វើដំណើរជួយអមដំណើរទៅណាត់ជួបពេទ្យ និងធ្វើការទិញទំនិញផងដែរ។

យើងខ្ញុំមានផ្តល់សេវាកម្មនេះដល់អ្នកដែលរស់នៅតំបន់ភាគខាងត្បូងនៃមែលប៊ិនផងដែរ។

## គម្រោងអ្នកស្ម័គ្រចិត្តមើលថែទាំមនុស្សចាស់ជរា (ACVVS)

គម្រោងអ្នកស្ម័គ្រចិត្តមើលថែទាំមនុស្សចាស់ជរាគឺជាកម្មវិធីជំនួយសង្គមដែលផ្តល់ឱ្យនូវមិត្តភាពនិងភាពជាដៃគូដល់មនុស្សចាស់ជរា។ការណាត់ជួបមានចំពោះអ្នកដែលភាពឯកោរស់នៅដាច់តែឯងស្នាក់នៅក្នុងមជ្ឈមណ្ឌលថែទាំចាស់ជរាឬអ្នកដែលទទួលបាន ឬរង់ចាំកញ្ចប់មើលថែរក្សានៅផ្ទះ។

កម្មវិធីនេះផ្តល់ជំនួយដល់មនុស្សចាស់ដែលមានអាយុចាប់ពី៦៥ឆ្នាំឡើងទៅដែលភាពឯកការក្នុងសង្គមតាមរយៈការធ្វើទស្សនកិច្ចសួរសុខទុក្ខរៀងរាល់សប្តាហ៍
ឬពីរសប្តាហ៍ម្តងពីក្រុមការងារស្ម័គ្រចិត្តដែលចេះភាសាចម្រុះរបស់យើងខ្ញុំ។
កម្មវិធីនេះផ្តល់សេវាសួរសុខទុក្ខនៅតាមមជ្ឈមណ្ឌលថែរក្សាចាស់ជរាមួយទល់មួយ ឬជាក្រុម និងសេវាមួយទល់មួយតាមផ្ទះចំពោះអ្នកដែលទទួលបានកញ្ចប់មើលថែតាមផ្ទះ។

សកម្មភាពរួមមាន៖

- ធ្វើដំណើរដើរលេង
- ផឹកកាហ្វេនិយាយគ្នាលេង
- លេងល្បែងវប្បធម៌ប្រជាប្រិយ៍ ឬមើលកម្មវិធីទូរទស្សន៍
- ចែករំលែកជំនាញផ្សេងៗដូចជាការប៉ាក់ការគូរគំនូរការលេងឧបករណ៍តន្រ្តី ជំនាញឌីជីថលជាដើម

## កម្មវិធីផ្តល់ជំនួយដល់អ្នកមើលថែ

កម្មវិធីផ្តល់ជំនួយដល់អ្នកមើលថែមានសិទ្ធិទទួលបានចំពោះអ្នកដែលធ្វើការមើលថែសមាជិកគ្រួសារ ឬមិត្តភក្តិដែលមានការប៉ះពាល់ដោយជម្ងឺ ពិការភាព បញ្ហាផ្លូវចិត្ត ឬការញៀន។

ក្នុងនាមជាអ្នកមើលថែ វាពិតជាសំខាន់ណាស់ក្នុងការថែទាំខ្លួនឯងដែលការងារនេះមានភាពលំបាក ហើយជាទូទៅអ្នកមើលថែទាំមានអារម្មណ៍ឯកោ។
សេវាកម្មយើងខ្ញុំរៀបចំឡើងដោយរួមបញ្ចូលនូវការផ្តល់ពេលវេលាសម្រាប់អ្នកមើលថែដែលចាំបាច់ក្នុងការសម្រាកមើលថែសុខុមាលភាពផ្ទាល់ខ្លួន រួមទាំងជំនួយបន្ថែមផ្សេងៗទៀតផងដែរ។

SMRC មានសកម្មភាព និងសេវាកម្មជាច្រើនដូចជា៖

- ការប្រជុំផ្តល់ជំនួយពីអ្នកធ្វើការជាមួយគ្នា
- វគ្គផ្តល់ព័ត៌មានជំនួយដល់អ្នកមើលថែក្នុងការបំពេញការងារថែទាំ
- ជំនួយអារម្មណ៍ផ្លូវចិត្ត
- ការដើរកម្សាន្តសង្គមរៀងរាល់ខែ
- សកម្មភាពជំនួយសុខភាពបន្ថែម
- ការសម្រាកលំហែដែលមានភាពបត់បែន
- ការប្រឹក្សាយោបល់
- ការប្រឹក្សាយោបល់ជីវិត

យោងតាមច្បាប់ទទួលស្គាល់អ្នកមើលថែ ២០១២ (the Carers Recognition Act 2012)
កម្មវិធីផ្តល់ជំនួយអ្នកមើលថែត្រូវបានទទួលស្គាល់
និងផ្តល់ជំនួយគាំទ្រដល់ទំនាក់ទំនងមើលថែទាំរវាងអ្នកមើលថែ និងអ្នកដែលទទួលបានការមើលថែ។
កម្មវិធីផ្តល់ជំនួយដល់អ្នកមើលថែតែងតែស្វែងរកវិធីសាស្រ្តក្នុងការលើកតម្កើនគុណភាពជីវិតរបស់អ្នកមើលថែ។ ប្រសិនបើអ្នកជាអ្នកមើលថែដោយឥតគិតថ្លៃរបស់នណារម្នាក់ សូមជម្រាបជូនដល់ GP របស់អ្នកដើម្បីទទួលបានជំនួយគាំទ្របន្ថែម។



## កម្មវិធីសម្រាកលំហែតាមការកំណត់របស់មជ្ឈមណ្ឌល

កម្មវិធីសម្រាកលំហែតាមការកំណត់របស់មជ្ឈមណ្ឌល
គឺជាកម្មវិធីសម្រាកលំហែតាមការកំណត់របស់មជ្ឈមណ្ឌលដែលរៀបចំរៀងរាល់សប្តាហ៍ក្នុងបរិយាកាសរួសរាយរាក់ទាក់ និងពោរពេញដោយការគាំទ្រ។ បុគ្គលិកភាសាចម្រុះរបស់ SMRC មានដំណើរការសកម្មភាពជាច្រើនរួមានលំហាត់ស្រាលៗ កម្រងសំណួរ ល្បែងខួរក្បាល និងការដើរលេងជាក្រុមប្រចាំខែ។ មានផ្តល់តែពេលព្រឹក និងអាហារថ្ងៃត្រង់ ព្រមទាំងរៀបចំមធ្យោបាយធ្វើដំណើរប្រសិនបើចាំបាច់។

យើងខ្ញុំរៀបចំកម្មវិធីនេះរៀងរាល់សប្តាហ៍។

## កម្មវិធីសម្រាកលំហែពាក់កណ្តាលសប្តាហ៍តាមការកំណត់របស់មជ្ឈមណ្ឌល

កម្មវិធីសម្រាកលំហែពាក់កណ្តាលសប្តាហ៍យើងខ្ញុំគឺជាក្រុមជំនួយផ្តល់ជូនអ្នកដែលមានបញ្ហាការចងចាំ ឬមានជំងឺវង្វេង។
ក្រុមជំនួយភាសាចម្រុះយើងខ្ញុំមានរៀបចំនូវសកម្មភាពមួយចំនួនដូចជារៀបល្បែងខួរក្បាល ការធ្វើលំហាត់ប្រាណ និងសកម្មភាពសង្គមផ្សេងៗ។
យើងខ្ញុំក៏មានរៀបចំដំណើរកម្សាន្តទៅកន្លែងផ្សេងៗរៀងរាល់ខែផងដែរ។

មានរៀបចំតែពេលព្រឹក និងអាហារថ្ងៃត្រង់

ព្រមទាំងមធ្យោបាយធ្វើដំណើរតាមតម្រូវការ។

កម្មវិធីនេះដំណើរការរៀងរាល់សប្តាហ៍។

## ជំនួយការក្នុងស្រុក

សេវាកម្មនេះផ្តល់ជំនួយដល់អ្នកប្រសិនបើអ្នកមិនអាចដើរទៅទិញទំនិញបាន។

បុគ្គលិកម្នាក់របស់យើងខ្ញុំនឹងធ្វើការទាក់ទងអ្នកពីទំនិញប្រចាំដែលអ្នកត្រូវការ ធ្វើការទិញទំនិញនោះតាមតំបន់និងដឹកជញ្ជូនទៅដល់ផ្ទះរបស់លោកអ្នក។
សេវាកម្មនេះដំណើរការរៀងរាល់សប្តាហ៍។
ការទូទាត់សំណងសម្រាប់ការទិញទំនិញគឺតម្រូវប្រគល់ឱ្យបុគ្គលិកបន្ទាប់ពីបានទិញទំនិញហើយដឹកជញ្ជូនដល់ផ្ទះ។



# Charter of Aged Care Rights

## នាយកដ្ឋានសិទ្ធិធម្មនុញ្ញ

## All people receiving Australian Government funded residential care, home care or other aged care services in the community have rights.

### I have the right to:

1. safe and high-quality care and services;
2. be treated with dignity and respect;
3. have my identity, culture and diversity valued and supported;
4. live without abuse and neglect;
5. be informed about my care and services in a way I understand;
6. access all information about myself, including information about my rights, care and services;
7. have control over and make choices about my care, and personal and social life, including where choices involve personal risk;
8. have control over, and make decisions about, the personal aspects of my daily life, financial affairs and possessions;
9. my independence;
10. be listened to and understood;
11. have a person of my choice, including an aged care advocate, support me or speak on my behalf;
12. complain free from reprisal, and to have my complaints dealt with fairly and promptly;
13. personal privacy and to have my personal information protected;
14. exercise my rights without it adversely affecting the way I am treated.

### If you have concerns about the aged care you are receiving, you can:

- talk to your aged care provider, in the first instance,
- speak with an aged care advocate on **1800 700 600** or visit **opan.com.au**, for support to raise your concerns, or
- contact the **Aged Care Quality and Safety Commission** on **1800 951 822** or visit its website, **agedcarequality.gov.au**. The Commission can help you resolve a complaint about your aged care provider.



## ស្តង់ដារគុណភាពការមើលថែមនុស្សចាស់ជរា

SMRC អនុវត្តស្តង់ដារគុណភាពការមើលថែមនុស្សចាស់ជរាដូចខាងក្រោមៈ






## កម្រៃ

លោកអ្នកនឹងត្រូវបង់ថ្លៃបន្តិចបន្តួចសម្រាប់ប្រើប្រាស់សេវាកម្មយើងខ្ញុំដែលហៅថាថ្លៃសេវាកម្ម។ ថ្លៃចំណាយផ្សេងៗទៀតអាស្រ័យទៅនឹងតម្រូវការជំនួយដែលលោកអ្នកត្រូវការដូចជាមធ្យោបាយធ្វើដំណើរ និងអាហារ។

យើងខ្ញុំយល់បានថាតម្លៃទាំងនេះអាចមានផលប៉ះពាល់ដល់សម្ពាធហិរញ្ញវត្ថុរបស់អ្នក ឬអាចប្រឈមមុខនូវបញ្ហាហិរញ្ញវត្ថុ។ SMRC យល់ និងផ្តល់នូវជំនួយដែលអ្នកត្រូវការ។ លោកអ្នកអាចការវាយតម្លៃហិរញ្ញវត្ថុ ហើយនឹងត្រូវការឆ្លងកាត់ដំណើរការវាយតម្លៃហិរញ្ញវត្ថុរបស់យើងខ្ញុំដើម្បីទទួលបានការបញ្ចុះតម្លៃ។

សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងតម្លៃ ឬចង់ពិភាក្សាពីការវាយតម្លៃហិរញ្ញវត្ថុ សូមលោកអ្នកទំនាក់ទំនងទៅកាន់អ្នករៀបចំកម្មវិធីដោយផ្ទាល់។

## មានអារម្មណ៍មិនស្រួលខ្លួន

ប្រសិនបើអ្នក ឬសមាជិកគ្រួសារអ្នកមានអាការផ្តាសាយធ្ងន់ គ្រុនផ្តាសាយ ឬមានអារម្មណ៍មិនស្រួលខ្លួន **សូមកុំចូលរួមកម្មវិធី SMRC ឱ្យសោះ។**

សូមមេត្តាមេត្តាជួយនិយាយទៅកាន់បុគ្គលិក ឬអ្នកសម្របសម្រួលកម្មវិធី បើមានសំណួរណាមួយ។

## ការឱ្យថ្នាំ

ក្រុមការងាររបស់ SMRC អាចជួយឱ្យថ្នាំបានតាមតែការកំណត់ជាក់លាក់ប៉ុណ្ណោះ។

ថ្នាំទាំងនោះរួមមាន ថ្នាំគ្រាប់ ថ្នាំទឹកភ្នែក វីតាមីន ថ្នាំត្រជាក់ប៉ារ៉ាសេតាម៉ុល ថ្នាំបាញ់ និងក្រេមលាប។

ក្រុមការងាររបស់ SMRC មិនអាចថ្នាំដល់អ្នកដៃបានទេ។ យើងអាចរំលឹកអ្នកក្នុងការផឹកថ្នាំតាមការកំណត់ ប៉ុន្តែមិនអាចយកថ្នាំទៅឱ្យដល់ដៃអ្នកទេ។ សូមទាក់ទងអ្នករៀបចំកម្មវិធីប្រសិនបើអ្នកមានចម្ងល់ទាក់ទងនឹងការឱ្យថ្នាំ។

## ការគ្រប់គ្រងពេលមានអាកាសធាតុមិនល្អ

នៅពេលមានអាកាស់ធាតុមិនល្អ
អ្នកគ្រប់គ្រងរៀបចំកម្មវិធីនឹងធ្វើការពិនិត្យមើលលក្ខខណ្ឌអាកាសធាតុ។ នៅរដូវក្តៅ ប្រសិនបើសីតុណ្ហភាពលើសពី35អង្សា សកម្មភាពខាងក្រៅទាំងអស់នឹងត្រូវបានផ្អាកដំណើរការ ហើយមានអនុវត្តសកម្មភាពខាងក្នុងដែលមានបំពាក់នូវប្រព័ន្ធម៉ាស៊ីនត្រជាក់។
SMRCនឹងកំណត់យកសកម្មភាពដែលមានសុវត្ថភាពសម្រាប់អ្នក
ព្រមទាំងពិភាកសារកម្មវិធីនោះជាមួយអ្នកផងដែរ។

CFA មានកម្រិតតសម្រាប់ហានិភ័យភ្លើងដូចខាងក្រោម៖




## ការលប់ចោលកម្មវិធី

ប្រសិនេបើលោកអ្នកមិនអាចចូលរួមកម្មវិធីបានេទ ត្រូវែតមានការលប់ចោលជាចាំបាច់។ រាល់កម្មវិធីទាំងអស់ែដលេយើងេរៀបចំ េលាកអ្នក្រតូវផ្តល់ដំណឹងដល់បុគ្គលិក ឬអ្នកេរៀបចំកម្មវិធី ក្នុងរយៈពេល២៤ម៉ោងជាមុន។
ប្រសិនជាឲយដំណឹងយឺត នឹង្រតូវបង់ការផាកពិន័យ។ ក្នុងសា□នការណ៍បនា□ន់ែដលេលាកអ្នកមិនអាចទាក់ទងមកេយើងបាេនាះ នឹងគា□នការបង់ផាកពិន័យេទ រួមមាន៖ េលាកអ្នកត្រូវបាេនគបញ្ជូនចូលេពទយ ដួល ឬឈឺស្កាត់ភា□ម។។

## ការឈប់ ឬផា□ស់ប្តូរកម្មវិធី

** ប្រសិនេបើអ្នកមិនចូលរួមក្នុងកម្មវិធីជំនួយសង្គមរបស្រ់កុមេលាកអ្នក SOCIAL SUPPORT GROUP ចំនួន៨សបា□ហ៍ េយើងនឹងពិភាកេសាតំរូវការរបស់អ្នក និងជួយែស្វងរកកម្មវិធីេផសងេទៀត ែដលសម្រសបសំរាប់េលាកអ្នក។
** ប្រសិនេបើសា□នភាពេលាកអ្នកមានកាែ្របែ្រប្រួល ឬេលាកអ្នកមិនចង់បន្តការចូលរួមក្នុងកម្មវិធីរបស់េយើងេដាយមូលេហតុណាមួយ សូម្របាប់ឲយេយើងខ្ញុំបានដឹង។ េយើងនឹងពិភាកេសាតំរូវការរបស់អ្នក និងជួយែស្វងរកកម្មវិធីេផសងេទៀតែដលសម្រសបសំរាប់េលាកអ្នក។
** េបើេលាកអ្នកចង់ប្តូរៃថ្ង សូម្របាប់ឲយេយើងដឹងេដើមបីពិភាកេសាគា□។

** េយើងអាចផ្តល់ព័ត៌មានពីេសវាកម្មេផសងៗ និងជួយេធ្វើលិខិតបញ្ជូនឲយបាន។

## េគាលការណ៍ឯកជនភាព

អង្គការេយើ្រងបកាន់ខា□ប់នូវការការពារការសំងាត់ផា□ល់ខ្លួនរបស់អតិថិជន េហតុេនះេហើយ SMRC អេសអឹមអសុី េគារពតាមេគាលការណ៍រកេសាការសំងាត់របស់ជាតិ NATIONAL PRIVACY PRINCIPLES ក្នុងកាេរេធ្វើការងារពាក់ព័ន្ធេទៅនឹងព័ត៌មានផា□ល់ខ្លួន។
េគាលការណ៍េនះត្រូវបានអនុវត្តចំេពាះអតិថិជនទាំងអស់ែដលេយើងផ្តល់េសវាកម្មជូន។
ព័ត៌មានផា□ល់ខ្លួនរបស់េលាកអ្នក នឹងអាចផ្តល់ដល់ភា□ក់ងាររបស់រដា□ភិបាលែដលផ្តល់េសវាកម្មដល់េលាកអ្នែកតប៉ុេណ្ណាះ។
ប្រសិនេបើេលាកអ្នកមានចម្ងល់ពាក់ព័ន្ធនឹងព័ត៌មានផា□ល់ខ្លួេនេនៅ SMRC អេសអឹមអសុី សូមេលាកអ្នកទាក់ទងមកកាន់ការិយាល័យេយើង េដើមបីែជកជាមួ្របធានកម្មវិធី។
















Public's Corner







## លេខទូរស័ព្ទមានប្រយោជន៍៖

**My Aged Care** សេវាកម្មរដ្ឋដែលជួយអ្នកក្នុងការស្វែងរកព័ត៌មាន និងសេវាកម្មមើលថែមនុស្សចាស់ជរា។

លេខទូរស័ព្ទ៖1800 200 422

**Elder Rights Advocacy** ជំនួយគាំទ្រមនុស្សវ័យចំណាស់ ក្រុមគ្រួសាររបស់ពួកគាត់ ព្រមទាំងតំណាងដែលមានប្រឈមនឹងបញ្ហាទាក់ទងនឹងមូលនិធិដែលផ្តល់ដោយ Commonwealth ក្នុងការថែទាំមនុស្សចាស់ជរាតាមរយៈការតស៊ូមតិ។

លេខទូរស័ព្ទ៖9602 3066

**Seniors Rights Victoria** ផ្តល់ព័ត៌មាន ជំនួយ យោបល់ និងការអប់រំក្នុងការការពារខ្លួនដល់មនុស្សចាស់ជរាទៅតាមសិទ្ធ ភាពថ្លៃថ្នូរ និងឯករាជ្យភាពនៃមនុស្សចាស់ជរា។

លេខទូរស័ព្ទ៖1300 368 821

**Office of the Public Advocate Victoria** លើកតម្កើនសិទ្ធិ ផលប្រយោជន៍ និងភាពថ្លៃថ្នូររបស់បុគ្គលដែលងាយរងគ្រោះ។

លេខទូរស័ព្ទ៖1300 309 337

**Carers Victoria** ផ្តល់យោបល់ ព័ត៌មាន និងជំនួយដល់អ្នកមើលថែមនុស្សចាស់ក្នុងការបង្កើនសុខភាព សុខុមាលភាព សមត្ថភាព និងភាពធន់អត់ធ្មត់។

លេខទូរស័ព្ទ៖9396 9500

**Carer Gateway** ផ្តល់ព័ត៌មានទៅកាន់អ្នកដែលផ្តល់សេវាមើលថែទាំដោយឥតគិតថ្លៃដល់ជនពិការ ជនស្ថិតក្នុងស្ថានភាពព្យាបាលសុខភាព ឬអ្នកដែលមានបញ្ហាសុខភាពផ្លូវចិត្ត។

លេខទូរស័ព្ទ៖1800 422 737



Southern
Migrant & Refugee Centre

39 Clow St, Dandenong VIC 3175
**P** 9767 1900
**E** smrc@smrc.org.au

www.smrc.org.au